# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៩ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** កែសម្រួល **គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ** ទៅជា **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** ដែលហៅកាត់ថា **គជបអ** និងជាអក្សរឡាតាំង ហៅកាត់ថា NCONIF ជាស្ថាប័នជាតិចំណុះផ្ទាល់រាជរដ្ឋាភិបាល ។

**មាត្រា ២ :** កែសម្រួលសមាសភាពគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដោយរក្សាឋានៈបច្ចុប្បន្ន មានដូចខាងក្រោម :

| | | |
|---|---|---|
| ១- | សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល | ប្រធាន |
| ២- | ឯកឧត្តម សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៣- | ឯកឧត្តម មិន ឃិន | អនុប្រធាន អចិន្ត្រៃយ៍ |
| ៤- | ឯកឧត្តម ជា សុខុម | សមាជិក អចិន្ត្រៃយ៍ |



Downloaded from http://www.khmerlaws.com

៥- ឯកឧត្តម ឌា តាន សមាជិក អចិន្ត្រៃយ៍

៦- ឯកឧត្តម ញ៉ៀម ម៉ាលី សមាជិក អចិន្ត្រៃយ៍

៧- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងព្រះបរមរាជវាំង សមាជិក

៨- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងការពារជាតិ សមាជិក

១០- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងមហាផ្ទៃ សមាជិក

១១- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១២- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៣- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១៤- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៥- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងសុខាភិបាល សមាជិក

១៦- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងធម្មការ និងសាសនា សមាជិក

១៧- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៨- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងពត៌មាន សមាជិក

១៩- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

២០- ឯកឧត្តម អគ្គស្នងការរង ០១ រូប តំណាង អគ្គស្នងការនគរបាលជាតិ សមាជិក

២១- ឯកឧត្តម អគ្គមេបញ្ជាការរង ០១ រូប តំណាង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

២២- ឯកឧត្តម អនុរដ្ឋលេខាធិការ ០១ រូប តំណាង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

២៣- តំណាង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ សមាជិក

២៤-ឯកឧត្តម-លោក អភិបាលរង ខេត្ត-ក្រុង ០១ រូប សមាជិក

**មាត្រា ៣ :** គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានតួនាទី និងភារកិច្ច លើកគំរោងផែនការ ស្តីអំពីរូបភាពចាត់តាំង តំណាងអោយពិធីការរដ្ឋ ក្នុងការរៀបចំកម្មវិធី និងគ្រប់គ្រងពិធីបុណ្យផ្សេងៗ ដូចជា បុណ្យប្រពៃណីជាតិ បុណ្យជាតិ បុណ្យអន្តរជាតិ ទទួលជូនដំណើរភ្ញៀវជាន់ខ្ពស់ជាតិ និងអន្តរជាតិ តាមការកំណត់របស់អង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងព្រះមហាក្សត្រ ។

**មាត្រា ៤ :** អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានភារកិច្ចរៀបចំបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ តាមការណែនាំរបស់ប្រធាន ។



Downloaded from http://www.khmerlaws.com

មាត្រា ៥ : ប្រធាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានសិទ្ធិលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេចការស្នើសុំតែងតាំង ឬផ្លាស់ប្តូរ ទីប្រឹក្សា និងជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

មាត្រា ៦ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានអនុប្រធានអចិន្ត្រៃយ៍ ០១រូប អមដោយសមាជិកអចិន្ត្រៃយ៍មួយចំនួនជាជំនួយការ ដឹកនាំចាត់ចែងការងារទូទៅរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

មាត្រា ៧ : អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានអចិន្ត្រៃយ៍ ។

មាត្រា ៨ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិមួយ ជាអង្គភាពចំណុះប្រតិបត្តិផ្ទាល់ ដែលត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ។ សមាសភាពថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដែលមានស្រាប់រួមមាន ៖

១- ឯកឧត្តម មិន ឃិន អគ្គលេខាធិការ គ.ជ.ប.អ

២- ឯកឧត្តម ជា សុខុម អគ្គលេខាធិការរងទី១ គ.ជ.ប.អ

៣- ឯកឧត្តម ជា តាន អគ្គលេខាធិការរង គ.ជ.ប.អ

៤- ឯកឧត្តម ញ៉ែម ឌ៉ាលី អគ្គលេខាធិការរង គ.ជ.ប.អ

៥- ឯកឧត្តម រស់ គន់ អគ្គលេខាធិការរង គ.ជ.ប.អ

៦- ឯកឧត្តម ឈិន គេតណា អគ្គលេខាធិការរង គ.ជ.ប.អ

អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដំណើរការការងាររបស់ខ្លួនដោយរក្សាឋានៈបច្ចុប្បន្នរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលមានស្រាប់ ។

មាត្រា ៩ : ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ប្រើប្រាស់រចនាសម្ព័ន្ធ អនុក្រឹត្យដែលមានស្រាប់ ។

មាត្រា ១០ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានសិទ្ធិប្រើប្រាស់ត្រាផ្ទាល់ខ្លួន ដើម្បីបំពេញការងាររបស់ខ្លួន ។

មាត្រា ១១ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ បំពេញការងារដោយប្រើប្រាស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងអាចទទួលនូវជំនួយឧបត្ថម្ភផ្សេងៗ ពីអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពជំនាញនានា ដើម្បីគាំទ្រដល់ការរៀបចំពិធីបុណ្យនីមួយៗ ។



Downloaded from http://www.khmerlaws.com

**មាត្រា ១២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានភារកិច្ចអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៨០៥.៣៧៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០០៥

លេខ ៣២៩-ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាឌី តាន់



Downloaded from http://www.khmerlaws.com